# រឿង

# កូនទន្សាយចេះស្តាប់បង្គាប់



ឆ្នាំ ២០១០

ថ្ងៃនេះជាថ្ងៃអាទិត្យ ម្ដាយទីណូ ក្រោកពីព្រលឹម។ ឃើញម្ដាយក្រោក ទីណូកូនទន្សាយក៏ស្ទុះក្រោកតាមដែរ។

ម្ដាយទីណូសរសើរកូនថាៈ "ថ្ងៃនេះកូនក្រោកពីព្រលឹមល្អណាស់"។



និយាយរួច ម្ដាយទីណូកាន់ធុងមួយទៅយួរ ទឹក ទីណូក៏យកកូនធុងតូចមួយទៅជួយយួរទឹក ម្ដាយដែរ រហូតដល់ពេញពាង។



ម្ដាយទីណូ ទៅជញ្ជូនអុសទុកក្នុងផ្ទះ ទីណូ
ក៏ជួយជញ្ជូនម្ដាយដែរ។



ម្ដាយទីណូអង្អែលក្បាលទីណូ ហើយសរសើរកូនថា៖ "ថ្ងៃនេះកូនល្អណាស់ កូនក្រោកពីព្រលឹម ហើយជួយធ្វើការម្ដាយទៀត។ ឥឡូវនេះ កូនឯងនៅចាំផ្ទះ រួចបិទទ្វារឱ្យជាប់ ហើយកុំចេញទៅលេងខាងក្រៅឱ្យសោះ ខ្លាចមានគ្រោះថ្នាក់ ព្រោះកូនឯងនៅតូចជាងគេ។ ម្ដាយទៅផ្សារទិញម្ហូបនិងនំចំណីមកផ្ញើកូន"។



ម្ដាយទីណូក៏ចេញទៅផ្សារ។ ទីណូបិទទ្វារដាក់គន្លឹះជាប់ រួចហើយយកសៀវភៅមកអាន។



នៅខាងក្រៅផ្ទះមានក្មេងៗ លេងស្រែក ឡូឡាអ៊ូអរ។ ទីណូបង្អើបបង្អួចលបមើល ទៅក្រៅឃើញកុមារជាច្រើន កំពុងលេង សប្បាយ។ ម៉ាវៗកូនឆ្មា និងត្នោតកូនពពែ មកបបួលទីណូ ឱ្យចេញមកលេងខាងក្រៅ។ ទីណូចង់ចេញទៅលេងជាមួយគេណាស់។ តែទីណូមិនហ៊ានចេញសោះ ព្រោះទីណូចាំ ជានិច្ចនូវបណ្តាំរបស់ម្តាយ។





មិនយូរប៉ុន្មាន ម្ដាយទីណូត្រលប់មកវិញ បាននាំចំណីនិងផ្លែឈើខ្លះមកផ្ញើទីណូ។ ពេលនោះទីណូក៏សុំម្ដាយចេញទៅលេងជាមួយកុមារនៅខាងក្រៅផ្ទះ។ ម្ដាយទីណូសរសើរកូនថាៈ "កូនល្អណាស់ចេះស្ដាប់បង្គាប់ម្ដាយ ឥឡូវកូនទៅលេងចុះ! តែឆាប់ត្រលប់មកវិញណា"។

ទីណូអរគុណម្ដាយហើយ រត់ចេញទៅលេងជាមួយមិត្តភ័ក្តិទៅ។

អ្នកនិពន្ធ : លោកស្រី តឹក ស៊ីផុន

អ្នករៀបរៀង : លោកស្រី ឈុំ សារ៉ានី

វិចិត្រករ : លោក អ៊ុត រឿន

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ សេចក្តីសម្រេចលេខ ១៣៨ អរ.សសរ.

ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យ

**គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ**

បោះពុម្ពលើកទី១ ចំនួន៥,០០០ក្បាល

រោងពុម្ពក្រសួងអប់រំ ឆ្នាំ១៩៩១

**អំណោយ អ៊ុយនីសេហ្វ**

DON DE L'UNICEF

បោះពុម្ពលើកទី២ដោយ : អង្គការគាំពារកុមារខ្មែរ (CYK)

ភ្នំពេញ ខែកក្កដា ឆ្នាំ២០១០

មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រៃសណីយ៍ជប៉ុនសម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ

ចំនួន : ៥,០០០ក្បាល

លេខ : CYK N10014

រោងពុម្ព : **J S R C** Printing House

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានអប់រំកុមារតូច

CYK

This aid project is supported by all participants in Japan's
Postal Saving for International Voluntary Aid.
និងអង្គការគាំពារកុមារខ្មែរ ( CYK )

9789996317071